# ថ្នាក់រៀនប្រវត្តិសាស្ត្រ
# នៅអតីតគុកខ្មែរក្រហម
# មន្ទីរស-២១



## បើកបង្រៀន : ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១

ពាក្យស្លោកខ្មែរក្រហមប្រឆាំងនឹងការអប់រំមួយនិយាយថា “អង្គការគ្មានទេសញ្ញាបត្រ មានតែសញ្ញាឃើញ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ” ។ ពាក្យស្លោកមួយទៀតនិយាយថា “ការរៀនអក្សរ រៀនលេខមិនសំខាន់ទេ ការសំខាន់គឺ ការងារ និងចលនាបដិវត្តន៍” ។ ជាលទ្ធផល ការសិក្សានៅតាមសាលារៀនជាផ្លូវការត្រូវបានហាមឃាត់ទាំងស្រុងនៅក្រោមការគ្រប់គ្រងប្រកបដោយភាពផ្តាច់ការ និងឃោរឃៅរបស់ខ្មែរក្រហម ។ របបនេះបានប្រែក្លាយសាលារៀន និងវត្តអារាមឲ្យទៅជាគុក ក្រោលគោ និងឃ្លាំងដាក់សម្ភារៈ ។

គុកទួលស្លែងដែលត្រូវបានស្គាល់ថាជាគុកសម្ងាត់ “ស-២១” បានបង្កើតឡើងនៅក្នុងបរិវេណអតីតវិទ្យាល័យពោពញាយ៉ាតដែលសាងសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះឲ្យទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ នៅទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេអ៊ីអា ឬកាហ្សេបេជាដើម ។ ជាទូទៅ ក្រុមគ្រួសារទាំងមូលរបស់អ្នកជាប់ចោទពីបទក្បត់ជាតិត្រូវចាប់ឃុំឃាំងទាំងអស់ ហើយជាញឹកញយអ្នកទោសទាំងនោះមិនបានដឹងអំពីមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងខ្លួនទេនៅពេលចាប់ខ្លួន ។ អ្នកទោសត្រូវឆ្មាំគុកធ្វើទារុណកម្មរហូតទាល់តែអ្នកទោសទាំងនោះសារភាពពីបទល្មើសទាំងឡាយដែលត្រូវបានចោទប្រកាន់មកលើខ្លួន ។ បន្ទាប់ពីបានសារភាពរួច អ្នកទោសម្នាក់ៗត្រូវបានគេកត់ចំណាំដើម្បីយកទៅសម្លាប់ ។

ក្រុមអ្នកជំនាញបានប៉ាន់ស្មានថា អ្នកទោសប្រហែលពី១ម៉ឺន៤ពាន់ទៅ២ម៉ឺននាក់ត្រូវបានឃុំឃាំង និងសម្លាប់នៅគុកទួលស្លែង ។ មានតែអ្នកទោសប្រមាណប្រាំពីរនាក់ប៉ុណ្ណោះដែលបានរួចរស់រានមានជីវិតពីគុកនេះបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅក្នុងសាលក្រមកាត់សេចក្តីអតីតប្រធានគុកទួលស្លែងឈ្មោះ កាំង ហ្គេក អ៊ាវ ហៅ ឌុច បានកំណត់ថា យ៉ាងហោចណាស់មានអ្នកទោសចំនួនប្រហែល១២.២៧៣នាក់ បានជាប់ឃុំនៅគុកទួលស្លែង ។ ដោយសារតែចំនួនអ្នកដែលនៅរស់រានមានជីវិតមិនសូវមានការចាប់អារម្មណ៍ អ្នកសារព័ត៌មានលោកខាងលិចភាគច្រើននៅតែប្រើប្រាស់តួលេខប្រាំពីរនាក់ដដែល ហើយតួលេខនេះត្រូវបានប្រើប្រាស់ម្តងហើយម្តងទៀតអស់រយៈពេលជាងសាមសិបឆ្នាំមកហើយ ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីបានធ្វើការស្រាវជ្រាវអស់រយៈពេលប៉ុន្មានឆ្នាំកន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានប៉ាន់ស្មានថា មានអ្នកទោសយ៉ាងតិច១៧៩នាក់ត្រូវបានដោះលែងពីគុកទួលស្លែងនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ហើយមានអ្នកទោសប្រមាណជា២៣នាក់ ដែលនៅរស់រានមានជីវិតនៅពេលវៀតណាមផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

បច្ចុប្បន្ន អគារទាំងបួននៅក្នុងបរិវេណគុកបង្កើតបានទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលបានបើកជាសាធារណៈនៅក្នុងឆ្នាំ១៩៨០ ។ នៅក្នុងរយៈពេលពីរបីខែនៃការចាប់ផ្តើមបើកសារមន្ទីរនេះមានប្រជាជនក្នុងស្រុកចំនួនជាង៣សែននាក់ និងជនបរទេសប្រមាណ ១ម៉ឺន១ពាន់នាក់បានចូលទស្សនាសារមន្ទីរនេះ ។ ប្រជាពលរដ្ឋនៅទូទាំងពិភពលោកបានមកទស្សនាសារមន្ទីរនេះ ហើយបច្ចុប្បន្នមានអ្នកមកទស្សនាជាមធ្យមចំនួនប្រហែល២៥០នាក់ក្នុងមួយថ្ងៃ ។ ប្រជាជនកម្ពុជាជាច្រើនបានមកសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដើម្បីស្វែងរកព័ត៌មានអំពីសាច់ញាតិដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម ។

ខណៈពេលដែលសារមន្ទីរសម្រេចបានដោយជោគជ័យនៅក្នុងការលើកកម្ពស់ការយល់ដឹងជាទូទៅទាក់ទងនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងររបស់ខ្មែរក្រហម សារមន្ទីរនេះនៅមានកង្វះខាតការអប់រំប្រវត្តិសាស្ត្រមួយដែលអាចធ្វើឲ្យបទពិសោធន៍នៃការមកទស្សនាសារមន្ទីរកាន់តែមានប្រយោជន៍ប្រកបដោយការអប់រំ និងគួរឲ្យចងចាំ ។ ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលនេះដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀនមួយត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការបង្រៀននិងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។



**រូបលើ** : កូនរបស់កម្មាភិបាលខ្មែរក្រហមកំពុងរៀនអក្សរនៅក្នុងជំរំជនភៀសខ្លួនមួយ នៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ នៅក្នុងឆ្នាំ១៩៨០ ។ រូបថត : ចេ ខហ្វម៉ាន់ ។ ប្រភព : បណ្ណសារដ្ឋាន មជ្ឈមណ្ឌលឯកសារកម្ពុជា ។

**រូបក្រោម** : ហ៊ឹម ហ៊ុយ (ពាក់អាវពណ៌ខៀវ) ជាអតីតមេឆ្មាំគុក ស-២១ និង នង ចាន់ផល (អាវពណ៌ស) ជាអតីតកុមារដែលរួចរស់រានមានជីវិតពីគុក ស-២១ ដែលបានបាត់បង់ឪពុកម្តាយនៅ គុកស-២១នេះ ។ ហ៊ឹម ហ៊ុយ និង នង ចាន់ផល កំពុងសម្រាកបន្ទាប់ចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ឲ្យសិស្សានុសិស្សរាប់ពាន់នាក់នៅក្នុងខេត្តកំពុងធំ ក្នុងប្រទេសកម្ពុជា ។ រូបថត : ហេង ស៊ីនិត្យ ។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**អ្នកបង្រៀន** : បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលបុគ្គលិកម្នាក់ៗមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រ ពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។

**វាគ្មិន** : អ្នកជំនាញជាតិនិងអន្តរជាតិ ដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែល នៅរស់រានមានជីវិតពីមន្ទីរស-២១ ។

## ប្រធានបទដែលត្រូវយកមកបង្រៀននិងពិភាក្សា :

- តើខ្មែរក្រហមជានរណា?
- របនាសម្ព័ន្ធរបស់ខ្មែរក្រហម
- ប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហម
- គោលនយោបាយការបរទេសរបស់ខ្មែរក្រហម
- សាលក្រមកាត់សេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?
- គោលនយោបាយក្នុងប្រទេសរបស់ខ្មែរក្រហម
- មន្ទីរស-២១ (គុកទួលស្លែង)
- ការដួលរលំនៃរបបខ្មែរក្រហម
- ភាពយន្តឯកសារ

## កាលវិភាគនៃការបង្រៀន :

ថ្ងៃពុធ វេលាម៉ោង ៩-១០ ព្រឹក

ថ្ងៃសុក្រ វេលាម៉ោង ២-៣រសៀល

## ទីកន្លែង :

អគារ “ក” ជាន់ទី២ បន្ទប់ទី៣

ថ្នាក់រៀនប្រវត្តិសាស្ត្រនេះរៀបចំឡើងដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
ឧបត្ថម្ភគាំទ្រដោយ រដ្ឋាភិបាលប្រទេសបែលហ្ស៊ិក ប្រទេសស៊ុយអែត និងសហរដ្ឋអាមេរិក

ព័ត៌មានបន្ថែម សូមទំនាក់ទំនាក់តាមទូរស័ព្ទលេខ : (៨៥៥) ២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល ស៊ើ សាយ្យាណា truthsayana.s@dccam.org

មជ្ឈមណ្ឌលឯកសារកម្ពុជា
www.dccam.org www.cambodiatribunal.org www.cambodiasri.org